**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ ក្រុមហ៊ុនផូគីថា រីសតនិងស្ប៉ា (ខេមបូឌា) បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាពរបស់ លោក Charles Henri-CHEVET ជានាយកគ្រប់គ្រងទូទៅ ស្តីពីការព្យួរកិច្ចសន្យាការងារមួយរយៈដោយមូលហេតុគ្មានអតិថិជន។

**សមាសភាពអ្នកចូលរួម៖**

**ក) ភាគីតំណាងក្រុមហ៊ុន**

| | |
|---|---|
| លោក Charles Henri-CHEVET | ជានាយកគ្រប់គ្រងទូទៅ |
| អ្នកនាង សំ សោភា | ជាប្រធានផ្នែកធនធានមនុស្ស |
| លោក ឡេង សុម៉ានិត | ជាលេខាកត់ត្រា |

**ខ) ភាគីតំណាងកម្មករនិយោជិត**

| | |
|---|---|
| លោក រឿង ស័ក្កា | ជាអនុប្រធានសហជីព |
| លោក ធីយ លីហុង | ជាហិរញ្ញិកសហជីព |

ក្រោយកិច្ចពិភាក្សាគ្នាយ៉ាងល្អិតល្អន់ ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោម៖

១) ក្រុមហ៊ុនសំរេចព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ២៦៥នាក់ (ស្រី ៩៤នាក់) រយៈពេល ១៥ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០។

២) ក្នុងកំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លារ ក្នុងមួយខែ។

៣) នៅពេលចប់ការព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតត្រូវចូលមកបំពេញការងារនៅកន្លែងដើមតាមតួនាទីនិងភារកិច្ចរបស់ខ្លួន។

កិច្ចប្រជុំនេះត្រូវបានចប់សព្វគ្រប់នៅថ្ងៃដដែល ទី២៧ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ០៥ រសៀល ក្រោមបរិយាកាសរីករាយ។

ថ្ងៃពុធ ៦កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០

| **បានឃើញនិងឯកភាព** | **បានឃើញនិងឯកភាព** |
|---|---|
| ជ. នាយកគ្រប់គ្រងទូទៅ | សហជីពនិងតំណាងកម្មករ |
| ព្រះរាជាណាចក្រកម្ពុជា ផូគីថា រីសត & ស្ប៉ា (ខេមបូឌា) PHOKEETHRA RESORT & SPA (CAMBODIA) Co., Ltd. ពាណិជ្ជកម្មរាជធានីភ្នំពេញ | រឿង ស័ក្កា អនុប្រធានសហជីព<br>ធីយ លីហុង ហិរញ្ញិកសហជីព |